# រឿង មហាចោរនៅទល់ដែន

## ភាគទី២៩

មានទូជិះសេះយ៉ាងលឿនស្ទុងបោលសំដៅទៅទិសខាងជើងកាត់ព្រៃមួយយ៉ាងធំ ដែលសម្បូរពោពាសទៅដោយរុក្ខជាតិធំតូចៗ អ្នកនឹងស្រលាញ់ប្រទេសខ្មែរក្រៃពេកៗ ដោយប្រទេសខ្មែរមានព្រៃជាធនធាន ហើយដែលកូនខ្មែរស្រាវយកមិនចេះអស់ៗ ខាងលើមេឃផ្កាយរះព្រោងព្រាតនាកណ្ដាលនភាល័យពណ៌បៃតងខ្ចី ជាតុអាកាសត្រជាក់ស្រួលរកប្រទេសណាមកប្រដូចគ្មានឡើយៗ បុរសស្រលាញ់ប្រទេសខ្មែរ ស្រលាញ់ជនជាតិខ្មែរ ស្រលាញ់នឹងសាច់នឹងឈាមអ្នក តែមាណពអាក់អន់ចិត្តយ៉ាងធំអនេកគឺខ្មែរមិនឯកភាជ្យៗ យាមទីពីរៗផ្កាយព្រឹករះត្រឡៃនៅទិសខាងកើតៗ អ្នកជិះសេះយើងអស់កម្លាំងយ៉ាងខ្លាំងៗ លបស្ដាប់ខាងក្រោយគ្មានឮសូរអ្វីសោះៗ ទឹកចិត្តដ៏រីករាយមកគ្របដណ្ដប់អ្នកៗ បរិយាកាសព្រួយភ័យបើកវាំងននចេញស្រឡះពីដើមទ្រូងដើម្បីទុកបរិវេណឲ្យសេរីភាពបញ្ចេញរស្មីឡើងៗ អ្នកឈប់នឹកនាដល់ខ្មាំងដែលដេញតាមប្រកិតអស់ពេលជាយូរមកហើយៗ ហើយបណ្ដោយសណ្ដានចិត្តឲ្យដើរលេងរាយមាយគ្មានទីដៅៗ ញើសដែលហូរៗ ចុះកុំឲ្យតែនៅក្នុងកណ្ដាប់ដៃខ្មាំងៗ គឺជាសំណាងមួយយ៉ាងធំហើយដែលបានរួចខ្លួននេះៗ ព្រឹត្តិការណ៍ក្នុងប៉ុន្មានថ្ងៃនេះ មានមកយ៉ាងខ្លាំងជ្រួលខ្លាំងៗ ក្នុងការតស៊ូដើម្បីសេរីភាព និងអាយុជីវិតនេះ មានទូនឹកឃើញកោប អគ្គី នាងយីហ៊ុប....មែន! នាងយីហ៊ុបគួរនឹកខ្លាំងជាងគេៗ នៅពីចម្ងាយលើទួលដំបូក ភ្នក់ភ្លើងមួយឆេះផ្ទុងៗកណ្ដាលទីងងឹត ឃើញបីដូចភ្លើងរបស់បិសាចកំណាចណាមួយៗ

- អីយ៉ា! ខ្មាំង ឬ មិត្ត?

មានទូភ័យញ័រក្នុងពោះឡើងវិញ ។ បុរសលោតចុះពីលើខ្នងសេះចងអាជានេយ្យ រួចក៏តាំងលូនសំដៅទៅទីដែលមានភ្លើង ដោយប្រយ័ត្នមិនឲ្យមានឮសូរអ្វីដល់តិចតួចឡើយ ក្នុងពេលកំពុងលូននេះ ឆ្កែមួយក៏ព្រុសឡូឡើងៗ អ្នកលបភ័យតក្កមានឹកថា ម្ដងនេះមុខជាស្លាប់មិនខានៗ មនុស្សប្អូននាក់ក្រោកច្រូងៗ បរិយាកាសស្ងប់ស្រួលក៏ប្រែទៅជាតឹងតែងយ៉ាងខ្លួ

អត្ថបទដោយ៖ មាស សុភាព

ខ្លាញ់។ អ្នកជុតភ្លើងត្រៀមខ្លួនព្រឹប ខ្វះរត់រកដាវ ខ្វះចក់បានព្រួញគ្រប់ៗគ្នា។ គឺជាទាហាន។ ជនអ្នកត្រៀមខិនៗខ្លួនទៅពួនពាយជាខ្សែតាមគល់ឈើ។ ថ្កេកាន់ព្រុសខ្លាំងឡើង សម្ងឹងទៅទិសដែលមានន្ទលូនមក។ ពួកអ្នកពោមភ្លើងកំហែងលាន់ឡើងថា :

- អ្នកណា ?

មាននូដែលគិតតែថយរត់ដកខ្លួន កាលបើឮសូរមាត់ស្រែកសួរនោះ ក៏សប្បាយចិត្តជាពន់ពេកដូចបានរស់ឡើងវិញម្តងទៀត ក្រោកឈរដើរទៅមុខស្ទុងឥតបង្អង់។ មាត់អ្នកសួរបន្ទឹទៀតថា :

- អ្នកណា? លោកគ្រូឬអី?* អឺ!

សួរមាត់ក៏ស្ទុះច្រូងច្រាងឡើង ជំនួសផ្ទៃដាវដែលយើងស្មានថា មុខជាបានឮនោះៗ

- អូ! លោកគ្រូ! លោកគ្រូ រើយ! អាកោបៗ
- អ៊ើយ
- អគ្គី! អគ្គីអ៊ើយ!
- អើយ
- លោកគ្រូទេរើយ!

អ្នកទាំងអស់គ្នារត់ទៅទទួលមាននូដែលសើចស្វាញដើរចូលកាន់តែជិតមក។ មាននូទះស្មាបុរសម្នាក់ដែលមានមាឌស្តើងខ្ពស់ដើមទ្រូងធំក្រអាញ

- ម៉េចមហាកាល សុខសប្បាយទេ?

បុរសឈ្មោះមហាកាលធ្វើគារវកិច្ចយ៉ាងគោរព រួចឆ្លើយយ៉ាងរាក់ទាក់តបវិញថា :

- បាទ! ចុះលោកគ្រូ?
- សុខសប្បាយជាទេ ។ កូនចៅទាំងអស់មានប៉ុន្មាន?
- រួមទាំងខ្ញុំបាទ ទាំងអាកោប ទាំអគ្គី ទាំងកូនទាហានបានដប់ប្រាំនាក់។

អត្ថបទដោយ៖ មាស សុភាព

ជនទាំងដប់ប្រាំនាក់ ដូចរៀបរាប់មកនេះ ឈរត្រង់ខ្លួនមុខញញឹមរកមានន្ទដែលញញឹមរកអ្នករាល់គ្នាវិញ។

- អើ! ប៉ុណ្ណឹងបានហើយ។

មហាកាលដែលមើលមុខមានន្ទធំជាងគេនោះ និយាយឡើងថា :

- ខ្ញុំមិនដឹងខ្លួនផង ស្រាប់តែអាកោបទៅដល់ផ្ទះខ្ញុំទាំងយប់។ ខ្ញុំសួរវាក្លាម មានការអី វាក៏រាយការណ៍ប្រាប់ខ្ញុំៗ ក៏ប្រមូលគ្នាមកភ្លាមបានតែប៉ុណ្ណឹងឯង។

មានន្ទចោលភ្នែកទាំងពីរយ៉ាងមេត្រីរាប់អានទៅលើមុខមហាកាល។

- ចុះអ្នកឯទៀតទៅណា?
- ហ៊ឺ! លោកគ្រូរកហៅគេមិនទាន់ ស្រទុំវានៅផ្ទះឬទេ ក៏មិនដឹងស្បែវែង និងអរុណមិននៅទេ។
- ទៅណា?
- បាទ! លោកគ្រូអើយ ខែនេះគេទៅទន្ទេបាត់អស់ហើយ។ នៅតែខ្ញុំទេមិនចេះសោះខាងផ្លូវទឹក។

អ្នកទាំងអស់គ្នា ដែលឈរជុំវិញជនទាំងពីរស្តាប់យ៉ាងជក់ចិត្ត ប្តីត្បិតតែកិច្ចសន្ទនានេះគ្មានជម្រៅអ្វីឡើយ។

- កាលណាពួកនោះមកវិញ?
- ប្រហែលកន្លះខែទៀត។

មានន្ទបែទៅកាន់ស្នាកោបវិញម្តង រួចសួរថា:

- ម៉េចកោប?

នាយកោបបញ្ឈរភ្នែកឡើងទៅលើផ្ទើអៀនប្រៀនឆ្លើយថា :

អត្ថបទដោយ៖ មាស សុភាព

- ខ្ញុំបាទភ័យណាស់ ដោយមិនដឹងថាយប់នោះ លោកគ្រូបែកទៅខាងណា។

មានន្ទសើចកាន់តែខ្លាំងឡើង លេចធ្មេញសស្គុស រួចបែរទៅរកនាយគីសហជីវិនចាស់ទៀត។

- គីភ័យដែរឬ?
- ខ្ញុំបាទវាយថយៗ រួចគេចផុតទៅ
- ទាំងអស់គ្នាមានត្រូវរបួសដែរឬអ្វី?
- បាទ ទេ!

នាយកោបក៏ឆ្លៀតបញ្ចូលសំឡេងខ្លួនជាមួយអគ្គីទៀតថា :

- បាទ ទេ!

មហាកាលកាត់ថា :

- ពួកនេះលោកគ្រូទុកចិត្តចុះ ថាវាយននៀលដូចត្រីក្រាញ់។

នាយកោបរឹតតែអៀនដោយគេបញ្ចោរបន្តិចនេះ យកម្រាមដៃលូកមាត់ ឱនមុខលួចសំឡក់មហាកាល។ ជនទាំងអស់គ្នាក៏សើចលាន់ឮក្អាកក្អាយ។ ទាំងពលទាហាន ទាំងមេទ័ព ទាំងមេ បន្ទាបមក គេទាំងអស់គ្នាសប្បាយរីករាយលើសធម្មតា។ នាយគីនឹកឃើញនិយាយថា :

- អុញហ្ន៎ ! ភ្លេចសួរលោកគ្រូ តើពិសាបាយហើយឬនៅ?
- នៅ តែខ្ញុំស្រេកទឹកណាស់ មានទឹកមួយផ្តិលទេ?

មហាកាលទាញដៃនាយកោបមកថ្វាយពីស្មាមានន្ទ ទះក្បាលមួយផ្ទង់រួចនិយាយថា :

- អូ! យកទឹកមកជូនលោកគ្រូ ។ កោប ! រួចមករកដាំបាយជូនលោកគ្រូទៀត។

នាយកោបជ្រុលតះៗទៅមុខៗ មានន្ទសួរទៅមហាកាលថា :

- មានអ្វីជាអាហារ?

អត្ថបទដោយ៖ មាស សុភាព

- មាន! លោកគ្រូសាច់ទន្សាយខ្ញុំទើបបាញ់បាន!
- អើ បានទន្សាយផង! នាំឲ្យពិបាកទេឬ?
- ទេ ! មិនអីទេលោកគ្រូ ធ្វើតែមួយសន្ទុះរួចហើយ។

ជនទាំងអស់មិនព្រមទៅណាឆ្ងាយពីមាននួសោះ ។ មាននួក៏និយាយអំពីស្ថានការណ៍បច្ចុប្បន្នឲ្យអ្នករាល់គ្នាស្ដាប់ រួចដាស់ទឹកចិត្តអ្នករាល់គ្នាថា :

- យើងត្រូវតែតស៊ូ។ ការពិបាកនេះតែជាការចាំបាច់។ ការនេះធំតែជាការដែលគេអាចសម្រេចបានដោយយើងពួតដៃគ្នាពុះពារឡើង។ ក្នុងសង្គ្រាមយើងកុំខ្លាច បើយើងខ្លាច ខ្មាំងបានចិត្តរឹតតែរីបរាយយើង ។

(សូមរង់ចាំតាមដានភាគទី៣០ នៅសប្ដាហ៍ក្រោយ)

អត្ថបទដោយ៖ មាស សុភាព